**សេចក្តីណែនាំរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និងមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក ស្តីពីការកែសំរួលគណៈកម្មការសំរបសំរួលសកម្មភាពបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន**

យោងគោលការណ៍ណែនាំរួមរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ទាំងអស់ស្តីពីសកម្មភាពបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន ។

មជ្ឈមណ្ឌលជាតិទាំងពីរសូមធ្វើការណែនាំដល់គ្រប់អង្គភាព-សេវាពាក់ព័ន្ធទាំងអស់លើការកែសំរួលគណៈកម្មការសំរបសំរួលសកម្មភាពបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូនដូចខាងក្រោម :

**១. គណៈកម្មការសំរបសំរួលសកម្មភាពបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន ត្រូវបញ្ចូលជាមួយគណៈកម្មការសំរបសំរួលសកម្មភាពថែទាំព្យាបាលបន្ត** (Continuum of Care Coordinating Committee: CoCCC) **នៅថ្នាក់ស្រុកប្រតិបត្តិ ។**

**២. គណកម្មការសំរបសំរួលសកម្មភាពថែទាំព្យាបាលបន្ត** (CoCCC) **ត្រូវបានកែសំរួលភារកិច្ច និងសមាជិកភាពដូចខាងក្រោម :**

**២.១. សមាជិកភាព**

| | | |
|---|---|---|
| ១. | អភិបាល ឬអភិបាលរងដែលការិយាល័យសុខាភិបាលស្រុកប្រតិបត្តិតាំងនៅ | ប្រធាន |
| ២. | ប្រធាន ឬ អនុប្រធានការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ | អនុប្រធាន |
| ៣. | ប្រធានក្រុមថែទាំព្យាបាលអ្នកផ្ទុកមេរោគអេដស៍/អ្នកជំងឺអេដស៍ក្នុងមន្ទីរពេទ្យបង្អែកដែលជាប្រធានឬអនុប្រធានមន្ទីរពេទ្យបង្អែក | សមាជិក |
| ៤. | អ្នកទទួលបន្ទុកការងារ VCCT | - |
| ៥. | ប្រធានផ្នែកជំងឺឆ្លង | - |
| ៦. | ប្រធានផ្នែកជំងឺកុមារ | - |
| ៧. | ប្រធានផ្នែកព្យាបាលជំងឺរបេង | - |
| ៨. | ប្រធានផ្នែកសម្ភពនៃមន្ទីរពេទ្យបង្អែក | - |
| ៩. | តំណាងក្រុមថែទាំតាមផ្ទះ និងតាមសហគមន៍ | - |

| | | |
|---|---|---|
| ១០. | តំណាងអង្គការមិនមែនរដ្ឋាភិបាលដែលគាំទ្រសកម្មភាព CoC | - |
| ១១. | តំណាងបណ្តាញអ្នកផ្ទុកមេរោគអេដស៍នៅថ្នាក់ស្រុក | - |
| ១២. | តំណាងសាសនា | - |
| ១៣. | អ្នកសំរបសំរួលកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍នៅថ្នាក់ស្រុកប្រតិបត្តិ | លេខាធិការ |
| ១៤. | ប្រធានផ្នែកគាំពារមាតា និងទារក និងជាអ្នកសំរបសំរួលការងារ PMTCT នៅថ្នាក់ស្រុកប្រតិបត្តិ | លេខាធិការ |

**២.២. ភារកិច្ចរបស់ CoCCC**

- ធានាថាគ្រប់ផ្នែកពាក់ព័ន្ធទាំងអស់នៅក្នុងស្រុកប្រតិបត្តិធ្វើការរួមគ្នាដើម្បីប្រើប្រាស់អោយបានប្រសើរនូវប្រភពធនធានដែលមាន ។
- រកអោយឃើញនូវតំរូវការ ភាពខ្វះចន្លោះ និងផ្នែកដែលត្រូវសហការ និងសំរបសំរួលក្នុងចំណោមដៃគូ និងការងារថែទាំព្យាបាលអ្នកជំងឺអេដស៍ និងសកម្មភាពបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូននៅស្រុកប្រតិបត្តិ ។
- កំណត់យន្តការសំរបសំរួលរវាងការថែទាំព្យាបាលអ្នកជំងឺអេដស៍នៅក្នុងមន្ទីរពេទ្យបង្អែក និងការថែទាំតាមផ្ទះ និងសហគមន៍
- ផ្តល់វេទិកាមួយទៀងទាត់សំរាប់ពិភាក្សាអំពីបញ្ហាទាក់ទងទៅនឹងការថែទាំព្យាបាលបន្តអ្នកជំងឺអេដស៍ និងសកម្មភាពបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន ។

**៣. ចំពោះខេត្ត-ក្រុងដែលមានសកម្មភាពថែទាំព្យាបាលបន្តចាប់ពី ពីរកន្លែង គប្បីបង្កើតក្រុមគាំទ្របច្ចេកទេស CoC ថ្នាក់ខេត្ត (Provincial CoC Support Group) ដែលមានសមាសភាពដូចខាងក្រោម :**

| | |
|---|---|
| • ប្រធានក្រុមគ្រប់គ្រងកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត-ក្រុង (HAMT) ដែលជាប្រធាន ឬ អនុប្រធានមន្ទីរសុខាភិបាល | ប្រធាន |
| • ប្រធានកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត-ក្រុង | សមាជិក |
| • ប្រធានកម្មវិធីគាំពារមាតា និងទារក និងជាអ្នកសំរបសំរួលសកម្មភាព PMTCT ខេត្ត-ក្រុង | សមាជិក |
| • ប្រធានកម្មវិធីប្រយុទ្ធនឹងជំងឺរបេងខេត្ត-ក្រុង | សមាជិក |
| • ប្រធាន ឬអនុប្រធានការិយាល័យបច្ចេកទេសនៃមន្ទីរសុខាភិបាលខេត្ត-ក្រុង | សមាជិក |
| • តំណាងអង្គការមិនមែនរដ្ឋាភិបាលដែលគាំទ្រដល់សកម្មភាព CoC | សមាជិក |
| • ជំនួយការប្រធានកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ទទួលបន្ទុក CoC | លេខាធិការ |

ភារកិច្ចសំខាន់របស់ក្រុមគាំទ្រនេះ គឺ :

- ចូលរួមធ្វើការវាយតំលៃនៅស្រុកប្រតិបត្តិដែលត្រូវរៀបចំអោយដំណើរការសេវាថែទាំព្យាបាលបន្ត
- ជួយណែនាំដល់ស្រុកប្រតិបត្តិក្នុងការបង្កើតប្រព័ន្ធគ្រប់គ្រងសេវាថែទាំព្យាបាលបន្ត
- អភិបាលការងារបច្ចេកទេសនៃសកម្មភាពសេវាថែទាំព្យាបាលបន្តនៅគ្រប់សេវា
- គៀងគធនធានដើម្បីជួយគាំទ្រដល់ដំណើរការការប្រព្រឹត្តទៅរបស់សេវាថែទាំព្យាបាលបន្តនៃស្រុកប្រតិបត្តិនិមួយៗ

៤. សេចក្តីណែនាំនេះនឹងត្រូវអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ប្រធានមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក

ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ